# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០១៣ ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស/ រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ .បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក.ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ ១៦ អនក្រ. បក. ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១** :- អាជីវកម្មសណ្ឋាគារ គឺជាការយកអាគារ សំរាប់ធ្វើអាជីវកម្មផ្គត់ផ្គង់បន្ទប់ស្នាក់នៅ ដែលមានបំពាក់នូវសំភារៈបរិក្ខារជូនភ្ញៀវ និងមានសេវាកម្មមួយចំនួនដូចជា ភោជនីយដ្ឋាន បានីយដ្ឋាន ហាងលក់ទំនិញ វត្ថុអនុស្សាវរីយ៍ កន្លែងហាត់ប្រាណ លេងកីឡា សាលប្រជុំ ព្រមទាំងមានសេវាកម្មពេញលេញទៅតាមតំរូវការរបស់ភ្ញៀវ ។ ទីតាំងសណ្ឋាគារស្ថិតនៅតាមទីប្រជុំជន ជាយក្រុង តំបន់រមណីយដ្ឋានទេសចរណ៍ និងតំបន់ដែលមានចលនាទេសចរណ៍ ។

- អាជីវកម្ម សេវាកម្មស្នាក់នៅទេសចរណ៍ផ្សេងទៀត ដូចជា ៖
  - សណ្ឋាគារអាផាតម៉ិន (Apartment Hotel ) ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅ និងបន្ទប់ស្វ៊ីតដោយបំពាក់គ្រឿងសង្ហារឹម សំភារៈបរិក្ខារ និងផ្តល់នូវសេវាកម្មដូចសណ្ឋាគារដែរ ហើយបំរើអោយការស្នាក់នៅរយៈពេលវែង ។ បន្ទប់ស្វ៊ីតមានបន្ទប់ស្នាក់នៅមួយ ឬច្រើន មានបំពាក់គ្រឿងសំភារៈផ្ទះបាយ និងមានបន្ទប់សំរាប់ទទួលភ្ញៀវ ។
  - សណ្ឋាគារ ស្វ៊ីត ( Suite Hotel ) ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅទាំងអស់សុទ្ធតែជាបន្ទប់ស្វ៊ីត ។
  - សណ្ឋាគាររីសត (Resort Hotel ) គឺជាសណ្ឋាគារដែលមានទីតាំងស្ថិតនៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ឆ្ងាយពីទីប្រជុំជន មានកន្លែងលំហែកាយសំរាកយកខ្យល់អាកាស មានផ្តល់សេវាកម្មម្ហូបអាហារភេសជ្ជៈ និងសេវាកម្មផ្សេងទៀតដែលធ្វើអោយចំរើនសុខភាព ដូចជាៈ វាយកូនគោល វាយតេនីស ស្ទូចត្រី ជិះសេះ ។
  - ម៉ូតែល (Motel) ជាអាគារមានមួយជាន់ ឬពីរជាន់ ដែលស្ថិតនៅតាមតំបន់ជាយក្រុង ឬតំបន់ដែលមានចលនាទេសចរណ៍ និងតាមបណ្តោយផ្លូវសំខាន់ៗ ផ្តល់នូវសម្បទា និងសេវាកម្មមានកំរិតសំរាប់បំរើអោយការស្នាក់នៅជាលក្ខណៈសំចតរយៈពេលខ្លី ។ មានភោជនីយដ្ឋានខ្នាតតូច មានចំណតរថយន្តធំទូលាយ និងអាចមានផ្តល់នូវសេវាកម្មសំរាប់កំសាន្តមួយចំនួន ។
  - ឡូដ៍ (Lodge) គឺជាអាគារ ដែលមានទីតាំងស្ថិតនៅតាមតំបន់សំរាកវិស្សមកាល ជនបទ ឬតំបន់ទាក់ទាញទេសចរសំរាប់បំរើអោយការស្នាក់នៅដល់ទេសចរមានលក្ខណៈជាពួក ឬ ជាក្រុមដែលមានគោលបំណងសំរាកលំហែកាយ និងកំសាន្តក្នុងសកម្មភាពនេសាទ បរបាញ់ កីឡា មានបំរើសេវាម្ហូបអាហារ និងភេសជ្ជៈ មានចំណតរថយន្ត ព្រមទាំងមានបំពាក់គ្រឿងសំភារៈផ្ទះបាយ ។
  - ប៊ិងហ្គាឡូ (Bungalow) គឺជាអាគារមួយជាន់មានលក្ខណៈជាភូមិគ្រឹះដាច់ៗពីគ្នា និងអាចមានច្រើនយូនិត (Units) នៅក្នុងអាគារតែមួយ ។ យូនិត (Units) នីមួយៗ មានបន្ទប់ដេកមួយ ឬច្រើន មានបន្ទប់ទទួលភ្ញៀវដាច់ដោយឡែក មានផ្ទះបាយ មានចំណតរថយន្ត ។ ប៊ិងហ្គាឡូ អាចជាអាគារសំណង់រឹង ឬស្រាល ។
  - ផ្ទះភ្ញៀវ (Guest House ) គឺជាអាគារដែលមានចំនួនបន្ទប់ពី ៥ ទៅ ១៩ បន្ទប់ មានបំពាក់ឧបករណ៍សំភារៈបរិក្ខារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសេវាបំរើភ្ញៀវមានកំរិត ។
  - ផ្ទះស្នាក់នៅ ( Homestay ) គឺជាសេវាកម្មស្នាក់នៅទេសចរណ៍ ដោយការរៀបចំលំនៅដ្ឋានរបស់ខ្លួនអោយទៅជាបន្ទប់មិនលើសពី ០៥ បន្ទប់ ឬជាគ្រែចល័ត ដូចជា ពៅអ៊ី ឬអង្រឹង មានបំពាក់សំភារៈបរិក្ខារ សាមញ្ញ និងសេវាមានកំរិត សំរាប់ទទួលបំរើការស្នាក់នៅរបស់ភ្ញៀវដែលមានបំណងមកសិក្សា និងស្វែងយល់ពីសកម្មភាពនៃជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍ និងរមណីយដ្ឋានក្នុងតំបន់ ។
  - កន្លែងបោះជំរុំទេសចរណ៍ (Tourist Camping ) គឺជាមូលដ្ឋានសេវាកម្មស្នាក់នៅទេសចរណ៍ ដោយប្រើប្រាស់តង់ (Tent) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ឆ្នេរសមុទ្រ មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មចាំបាច់មួយចំនួនដើម្បីបំរើទេសចរ ។

**ប្រការ ២ ៖** ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍អោយប្រកបអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងការផ្អាកការដកហូតបិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៣ :** ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូចខាងក្រោម :

ក - លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី

ខ - លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គ - វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ឃ - លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ង - លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល

ច - អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ឆ - លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនជាអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ

ជ - សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ពីការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍

**ប្រការ ៤ :** អាជ្ញាប័ណ្ណទេសចរណ៍ ត្រូវបានចេញអោយប្រើប្រាស់ ក្រោយពីអាជីវករបានបំពេញសំណុំឯកសារក្នុងការដាក់ពាក្យសុំធ្វើអាជីវកម្មគ្រប់គ្រាន់ និងត្រឹមត្រូវយ៉ាងយូរក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានដាក់ពាក្យ។ ក្នុងករណីដែលក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងបដិសេធមិនផ្តល់ ឬមិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួង ឬ មន្ទីរទេសចរណ៍នឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរជូនដល់អាជីវករ មិនលើសពី ១០ ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យ ។

**ប្រការ ៥ :** - នៅពេលអ្នកស្នើសុំអាជ្ញាប័ណ្ណបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចមានកំណត់ក្នុងប្រការ ៣ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្ម ដែលមានសុពលភាពរយៈពេល ០១ ឆ្នាំ។

- ក្នុងករណីអាជីវករមិនបានបំពេញបែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា នោះអាចស្នើសុំដោយធ្វើកិច្ចសន្យាសុំជំពាក់ឯកសារជាបណ្តោះអាសន្ននិងធានាបំពេញវិញក្នុងរយៈពេល ០៣ខែ។ បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យា នោះក្រសួង ឬមន្ទីរទេសចរណ៍នឹងផ្តល់អាជ្ញាប័ណ្ណដែលមានសុពលភាព ០១ ឆ្នាំ ជូនដល់អាជីវករ ។

**ប្រការ ៦ :** អាជ្ញាប័ណ្ណទេសចរណ៍មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល០១ឆ្នាំគិតពីថ្ងៃចេញច្បាប់អនុញ្ញាត។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវដាក់ពាក្យសុំបន្ត ដោយភ្ជាប់ជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន ០១ ខែ មុនថ្ងៃផុតកំណត់ ។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួង ឬ មន្ទីរទេសចរណ៍ពិនិត្យសំរេចលើលក្ខណៈសម្បត្តិក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម ។

**ប្រការ ៧ :** ពេលមានការផ្ទេរ លក់ ជួល ជួសជុល បិទអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវដាក់ពាក្យសុំតាម

រយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង អោយបានមុន ០៣ខែមកក្រសួងទេសចរណ៍ ។

**ប្រការ ៨ :** ការបង់ប្រាក់ក្នុងការចេញអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីសុំបើកអាជីវកម្មដំបូង ឬបន្តត្រូវបានកំណត់ដូចខាងក្រោម :

**ក. សណ្ឋាគារ ឬសណ្ឋាគារអាផាតម៉ិន ឬសណ្ឋាគារស្វ៊ីត ឬសណ្ឋាគាររីសត ឬប៊ឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសំរាប់១ឆ្នាំ ។**

| | |
|---|---|
| - ពី ១០ បន្ទប់ចុះ | ១៥០.០០០ រៀល |
| - ពី ១១ ដល់ ២០ បន្ទប់ | ២៥០.០០០ រៀល |
| - ពី ២១ ដល់ ៣០ បន្ទប់ | ៤០០.០០០ រៀល |
| - ពី ៣១ ដល់ ៦០ បន្ទប់ | ៦០០.០០០ រៀល |
| - ពី ៦១ ដល់ ១០០ បន្ទប់ | ៨០០.០០០ រៀល |
| - ពី ១០១ ដល់ ១៥០ បន្ទប់ | ១.២០០.០០០ រៀល |
| - ពី ១៥១ ដល់ ២០០ បន្ទប់ | ១.៦០០.០០០ រៀល |
| - ពី ២០១ ដល់ ៣០០ បន្ទប់ | ២.០០០.០០០ រៀល |
| - ពី ៣០០ បន្ទប់ឡើងទៅ | ២.៤០០.០០០ រៀល |

**ខ. ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណ ១០.០០០រៀល ក្នុង ០១បន្ទប់ សំរាប់១ឆ្នាំ**

**គ. កន្លែងបោះជំរុំត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសំរាប់១ឆ្នាំ**

| | |
|---|---|
| - ទំហំក្រោម ៤ហិកតា | ៦០០.០០០ រៀល |
| - ទំហំលើស ៤ហិកតា | ១.០០០.០០០ រៀល |

**ឃ.** ការបន្តអាជីវកម្មត្រូវបង់ ៥០% នៃចំនុច ៨ក- ៨ខ និង៨គ ។

ង. ការផ្លាស់ប្តូរអ្នកគ្រប់គ្រងដើម្បីបន្តសកម្មភាពអាជីវកម្មត្រូវបង់ ១០% នៃទឹកប្រាក់ដែលចែងក្នុងប្រការ ៨ ក- ៨ខ និង៨គ ។

**ប្រការ ៩ :**
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណដំបូង ឬអាជ្ញាប័ណ្ណបន្ត ព្រមទាំងទទួលយកអាជ្ញាប័ណ្ណទេសចរណ៍នៅមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។
- មន្ទីរទេសចរណ៍ខេត្ត-ក្រុងត្រូវចេញអាជ្ញាប័ណ្ណទេសចរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២ថ្ងៃនៃថ្ងៃធ្វើការដោយអនុលោមតាមប្រការ៣នៃប្រកាសនេះ ។
- ចំពោះអាជ្ញាប័ណ្ណដែលត្រូវពិនិត្យនិងសំរេចដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ត្រូវទទួលពាក្យសុំ និងចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ហើយបញ្ជូនមកក្រសួងទេសចរណ៍ក្នុងរយៈពេល ០៥ថ្ងៃ នៃថ្ងៃធ្វើការ។ ក្រសួងទេសចរណ៍ (នាយកដ្ឋានឧស្សាហកម្មទេសចរណ៍) ត្រូវទទួល និងពិនិត្យពាក្យសុំនេះ ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ។ ករណីចាំបាច់ ក្រសួងទេសចរណ៍អាចចុះត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្មនោះក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ ដែលរួចជាស្ថាពរទៅមន្ទីរទេសចរណ៍ក្នុងរយៈពេល ០៣ ថ្ងៃ ។

**ប្រការ ១០:** - អាជីវករដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ ។

- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍បណ្តោះអាសន្ន ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

**ប្រការ ១១:** - ករណីការធ្វើអាជីវកម្មដោយ :

ក ) ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬ អនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលការផាកពិន័យមានចំនួនទឹកប្រាក់ ២០០% ( ពីររយភាគរយ ) នៃថ្លៃបង់។ ប្រសិនបើអាជីវករមិនបង់ប្រាក់ផាកពិន័យនេះ ក្នុងរយៈពេល ០៣ខែ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្តក្រុងនឹងផ្អាកការធ្វើអាជីវកម្ម ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ បិទអាជីវកម្ម ។

ខ ) គ្មានអាជ្ញាប័ណ្ណទេសចរណ៍ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ។ ក្នុងករណីអាជីវករមិនអនុវត្តតាមការណែនាំក្រោយពីការព្រមាន នោះនឹងត្រូវបិទអាជីវកម្ម ។

គ) អាជីវករបានផ្តល់ព័ត៌មានមិនពិត ឬប្រឌិតឯកសារពាក់ព័ន្ធទៅនឹងពាក្យសុំធ្វើអាជីវកម្ម ក្រសួងទេសចរណ៍មានសិទ្ធិដកអាជ្ញាប័ណ្ណទេសចរណ៍ ឬ ផ្អាកអាជីវកម្ម ។

ឃ) ក្នុងករណីអាជីវករប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋ នឹងត្រូវដកហូតអាជ្ញាប័ណ្ណបិទអាជីវកម្ម ព្រមទាំងត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

**ប្រការ ១២:** នៅពេលមូលដ្ឋានអាជីវកម្មត្រូវទទួលការផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក័អក្សរផ្ញើដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម ។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដោយប្រការណាមួយ ឬក៏សាមីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់ សេចក្តីជូនដំណឹងនេះនឹងត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬមូលដ្ឋានអាជីវកម្ម ហើយត្រូវផ្ញើដល់សមាគមទេសចណ៍ក្នុងស្រុក និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីទុកជាព័ត៌មាន។

**ប្រការ ១៣:** ការផ្អាក ដកហូតអាជ្ញាប័ណ្ណទេសចរណ៍មានរយៈពេលកំណត់មិនលើសពី ០៦ខែ។ ក្នុងករណីអាជ្ញាប័ណ្ណត្រូវបានផ្អាក ឬដកហូត មូលដ្ឋានអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពឡើយ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូតនេះ ម្ចាស់អ្នកគ្រប់គ្រង ត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ។

**ប្រការ ១៤:** បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬ ផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំមិនត្រឹមត្រូវផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលនូវវិធានការរដ្ឋបាល ឬទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ១៥:** ០៣ ខែក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍នឹងមិនអនុញ្ញាតអោយធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ។

**ប្រការ១៦៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១៧៖** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង (ដើម្បីមុខការ)
- គ្រប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ